# របាំប្រពៃណីខ្មែរ៖ ការបង្កើត ផ្លាស់ប្តូរ និងថែរក្សា

របាំប្រពៃណីខ្មែរ កើតចេញមកពីសិកម្មរបស់ខ្មែរ ធម្មជាតិ និងបរិស្ថាន ព្រមទាំងនៅជាប់យ៉ាងជិតស្និទ្ធជាមួយនឹងប្រជាពលរដ្ឋកសិករស្រែចម្ការខ្មែរ។ ម្យ៉ាងទៀត របាំប្រពៃណីខ្មែរ មានប្រភពនិងមូលដ្ឋានពីជំនឿអរូបី សាសនា ទំនៀមទម្លាប់ ប្រពៃណី និងមនោសញ្ចេតនារបស់ខ្មែរ។ របាំនេះ ត្រូវបានគេបង្កើតឡើងនិងប្រតិបត្តិនៅក្នុងរង្វង់ និងបរិបទសហគមន៍ និងសេរីភាពរហូតមកដល់សព្វថ្ងៃនេះ។ អ្នករាំរបាំប្រពៃណី ជាកសិករ ដែលនាំគ្នាបង្កើតក្រុមរបាំនៅក្នុងភូមិរបស់គេ ដើម្បីកែកម្សាន្តនិងញុំាងពិធីបុណ្យទានផ្សេងៗឱ្យមានភាពអធឹកអធម។

## ការបង្កើតក្រុមរបាំប្រពៃណី

នៅមុនពេលគេបង្កើត "អភិរក្សមន្ទីរជាតិនៃទស្សនីយភាព" *Conservatoire National des Spectacles* (National Conservatory of Performing Arts) ដែលសព្វថ្ងៃ "នាយកដ្ឋានសិល្បៈទស្សនីយភាព" (Department of Performing Arts) និង សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្រុមរបាំប្រពៃណីខ្មែរ ត្រូវបានគេបង្កើតឡើងនិងគ្រប់គ្រងនៅក្នុងស្ថានភាពក្រោមអាជីព។ គេសម្តែងតែមួយដងមួយកាល នៅពេលដែលគេត្រូវការតែប៉ុណ្ណោះ។ ទើបតែនៅក្រោយពេលដែលគេបង្កើតអភិរក្សមន្ទីរជាតិនៃទស្សនីយភាព និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ សាកលវិទ្យាល័យបានដាក់បញ្ចូលរបាំប្រពៃណីនេះ ទៅក្នុងកម្មវិធីសិក្សាដែលជាមុខវិជ្ជា «របាំប្រពៃណី» ដើម្បីបណ្តុះបណ្តាលអ្នករាំ សិល្បករ និងសិល្បការិនីឱ្យក្លាយជាអ្នករាំ សិល្បករ និងសិល្បការិនីរបាំប្រពៃណីអាជីព ព្រមទាំងទទួលបាននូវ "ស្នាតកបត្រសិល្បៈ" ដែលមានតួនាទីជាអ្នកថែរក្សានិងបន្តវេនរបាំប្រពៃណីខ្មែរផង។

គឺពេលនោះហើយដែលរបាំប្រពៃណីខ្មែរភាគច្រើនបានត្រូវគេបង្កើតឡើង ដោយមានការគាំទ្រនិងទទួលស្គាល់ពីសាធារណជនទូទៅ និងបានក្លាយទៅនៅក្នុង"បញ្ជីអចិន្ត្រៃយ៍" (Permanent Repertoire)។ ដំណើរទស្សនកិច្ចសម្តែងទូទាំងប្រទេសនិងបរទេសត្រូវបានគេ

រៀបចំជាពិសេសក្រោមកិច្ចដឹកនាំដ៏មានប្រសិទ្ធភាព របស់លោក ឆេង ផុន នាយកផ្នែករបាំប្រពៃណីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងជានាយកនៃអគ្គិរក្សមន្ទីរជាតិនៃទស្សនីយភាព។

## ការផ្លាស់ប្តូរ

"ការផ្លាស់ប្តូរ" មិនគ្រាន់តែជាការចៀសមិនផុត តែជាតម្រូវការចាំបាច់ គឺនៅមានប្រសិទ្ធភាព សូម្បីតែនាពេលបច្ចុប្បន្ននេះ។ ការផ្លាស់ប្តូរនៃគំនិត រូបភាព ស្ថានភាព ចរិតលក្ខណៈ និងវប្បធម៌ បានទុកនូវស្នាមជាប់ក្នុងជំហរនៃរបាំនៅក្នុងសង្គមខ្មែរ។ របៀបរាំរបាំពីបុរាណ ហាក់ដូចជាមានការខ្វះខ្វាយមិនយកចិត្តទុកដាក់ពីសំណាក់អ្នកបតិបត្តក្រោមកំរិតអាជីព ដោយខ្វះចំណេះដឹងពិតប្រាកដអំពីរបាំព្រមទាំងការយល់ដឹងដែលជាកត្តាសំខាន់ក្នុងការបណ្តុះបណ្តាលបន្តវេននិងថែរក្សាប្រពៃណីចាស់ឱ្យគង់វង្ស។

នៅពេលដែលសិល្បករសិល្បការិនីនៃស្ថាប័នអាជីព ចំណុះឱ្យអគ្គិរក្សមន្ទីរជាតិ នៃទស្សនីយភាពនិងសាកលវិទ្យល័យភូមិន្ទវិចិត្រសិល្បៈ ចុះទៅធ្វើការស្រាវជ្រាវ សិក្សាប្រមូលទិន្នន័យពាក់ព័ន្ធនឹងរបាំប្រពៃណីខ្មែរ សិល្បករសិល្បការិនីអាជីព ក៏មានការកែប្រែ កាត់កងផ្លាស់ប្តូរចំណុចខ្វះដែលចាំបាច់ ដើម្បីកែលម្អ និងធ្វើឱ្យរបាំប្រពៃណីកាន់តែប្រសើរឡើងរួមទាំងចលនា ក្បាច់ ក្រឡារបាំ និងតន្ត្រី ជាដើម។ ខ្លឹមសារ ក៏ត្រូវកែខ្វះ ដើម្បីឱ្យស៊ីនិងសមស្របទៅនឹងបច្ចុប្បន្នភាពសោភ័ណ សិល្បៈ អប់រំ និងនយោបាយស្រុក។ របាំប្រពៃណីខ្មែរដែលអាចនៅរស់រានមានជីវិតបាន ដោយសារតែការផ្លាស់ប្តូរបត់បែនទៅតាមតម្រូវការចាំបាច់នៃពេលវេលាសមស្រប នយោបាយ និងសង្គមនេះឯង។ ដូច្នេះ យើងឃើញមានការផ្លាស់ប្តូរក្នុងពេលសន្តិភាពនិងពេលសង្គ្រាម។ ក្នុងពេលសន្តិភាព របាំប្រពៃណីមានតួនាទីជាការកែកម្សាន្តដែលខ្លឹមសារឆ្លុះបញ្ចាំង។ ក្នុងពេលសង្គ្រាម របាំប្រពៃណីក៏មានការផ្លាស់ប្តូរទៅតាមតម្រូវការនៃនយោបាយប្រទេសជាតិដែរ ទាំងសម្លៀកបំពាក់ តន្ត្រី ពាក្យពេចន៍ដែលមានឧទាហរណ៍ ដូចជារបាំគោះត្រឡោក និង របាំស្នា ជាដើម។ សូម្បីតែអ្នកដែល

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ស្រឡាញ់និងគាំទ្រ របាំប្រពៃណីខ្មែរ ក៏បានបង្ហាញនូវភាពខុសគ្នា មិនប្រក្រតីនៃក្បាច់ក្រឡារបាំ និងតន្ត្រីដែរ ដោយសារការបង្រៀននិងបង្ហាញខុសគ្នា ពីគ្រូមួយទៅគ្រូមួយទៀត ពីអ្នករាំម្នាក់ទៅអ្នករាំម្នាក់ទៀត នៅក្នុងអំឡុងពេលកន្លងមក។

នៅក្នុងបរិបទសកលភាវូបនីយកម្ម រួមមានការលូតលាស់កំពូលនិងទំនើបនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងកម្មវិធីនិងមធ្យោបាយសម្បូណ៌បែប ប្រកបដោយគុណភាពខ្ពស់ ដែលបាននិងកំពុងហូរចូលមកកម្ពុជាយ៉ាងគគ្រឹកគគ្រេង របាំប្រពៃណីខ្មែរក៏កំពុងតែមានការប្រឈមនៅក្នុងរឿងនេះ។ លើសពីនេះទៅទៀត ការព្រួយបារម្ភខ្លាំងនោះគឺ ការស្រុតចុះនៃគុណភាពរបាំប្រពៃណី ដោយសារចំណេះដឹងស្ទើរ កង្វះការយល់ដឹងជ្រៅជ្រះ ឯកទេសអាជីពនៅមានកំរិត រួមទាំងការមិនយកចិត្តទុកដាក់ចំពោះទម្រង់និងអាជីពនេះ។

## ការថែរក្សា

ការថែរក្សាវប្បធម៌និងរបាំប្រពៃណីខ្មែរ មានដំណើរការមកជាយូរណាស់មកហើយ ជាពិសេសគួរជាការកត់សម្គាល់នៅក្នុងទសវត្សឆ្នាំ១៩៦០ និងដើមទសវត្សឆ្នាំ១៩៧០។ នៅក្រោមកិច្ចដឹកនាំរបស់លោក ឆេង ផុន នាយកនៃផ្នែករបាំប្រពៃណី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងជានាយកនៃអភិរក្សមន្ទីរជាតិនៃទស្សនីយភាព លោកបានដឹកនាំការបណ្តុះបណ្តាល រៀនសូត្រ ហ្វឹកហាត់ចម្រៀងនិងរបាំ ទស្សនកិច្ចសម្តែងទូទាំងប្រទេសនិងបរទេស។ គឺនៅក្នុងអំឡុងពេលនោះហើយ ដែលរបាំប្រពៃណីខ្មែរមានការរីកចម្រើនដុះដាលនិងមានភាពប្រសើរក្នុងចំណុចចលនានិងក្រឡារបាំ សម្លៀកបំពាក់ ការតុបតែងឆាក ការបញ្ចាំងភ្លើង ការបំពងសំឡេង តន្ត្រី និងចម្រៀង ក៏ដូចជាបានលើកកម្ពស់ទម្រង់របាំនេះឱ្យមានស្តង់ដារខ្ពស់ ព្រមទាំងទាក់ទាញនិងធ្វើឱ្យទស្សនិកជនមានការគាំទ្រយ៉ាងសស្រាក់សស្រាំជាទីមោទនៈ។ លោក ឆេង ផុន បានផ្តល់និងទុកឱ្យសិស្សគណជំនាន់ក្រោយនូវពាក្យនិងទិសស្លោកមួយ ដែលមានន័យខ្លឹមសារថា៖ "បុរាណមិនយឺតថយក្រោយ សម័យមិនលឿនទៅមុខ" (Traditional is not backward, modern is not

advanced) គឺវាស្ថិតនៅលើអ្វីដែលយើងធ្វើនិងធ្វើដូចម្តេច ដែលឥឡូវនេះ យើងពោលថា៖ "បុរាណមិនយឺត សម័យមិនបរទេស" (Traditional is not backward, modern is not foreign)។

នៅក្នុងអំឡុងទសវត្សឆ្នាំ១៩៦០និងដើមទសវត្សឆ្នាំ១៩៧០ យើងបានចាត់ឱ្យមានក្រុមចុះទៅធ្វើការស្រាវជ្រាវបែបជាតិពន្ធុពណ៌នា (Ethnographic researches) នៅតាមសហគមន៍នានានៅកម្ពុជា ដូចជាក្នុងចំណោមជនជាតិដើមភាគតិចនៅភូមិភាគឥសាន្ត ខេត្តរតនគិរី និងមណ្ឌលគិរី ព្រមទាំងខេត្តមួយចំនួនមាន ឧត្តរមានជ័យ សៀមរាប បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ ជាដើម។ល។

## បច្ចុប្បន្នភាពនៃរបាំប្រពៃណីខ្មែរ

កន្លងមក យើងឃើញមានការខិតខំប្រឹងប្រែងថែរក្សាវប្បធម៌និងរបាំប្រពៃណីខ្មែរ ព្រមទាំងការបង្កើតនិងអភិវឌ្ឍបន្ថែមនៃទម្រង់នេះ។ ដោយឡែក ជារៀងរាល់ឆ្នាំលើកលែងតែក្នុងសម័យកូវីដ-១៩នេះ ដែលយើងតែងតែប្រារព្ធធ្វើ "ទិវាវប្បធម៌ជាតិ៣មីនា" ផ្តល់ជាឱកាសនិងវេទិកា ជូនដល់សិល្បករសិល្បការិនី ជាពិសេសយុវវ័យ ដើម្បីចូលរួមចំណែកលើកស្ទួយវប្បធម៌ និងបង្កើតស្នាដៃ បង្ហាញទេពកោសល្យក្នុងទម្រង់របាំប្រពៃណី។ នៅក្នុងវេទិកានេះ សិស្សនិស្សិតមកពីសាលាមធ្យមសិក្សានិងសាកលវិទ្យាល័យទាំង២៥ខេត្តក្រុង ទូទាំងប្រទេសបាននាំយកមកបង្ហាញ ទស្សនិកជននូវស្នាដៃរបាំប្រពៃណីបង្កើតថ្មីដូចជា របាំសម្រស់មច្ឆាមេគង្គ របាំសម្រស់មច្ឆាប៉ាស៊ីអ៊ី របាំរកជ័ររុង និងរបាំផលិតអំបិល ជាដើម។ល។ យ៉ាងណាមិញ នេះជាចំណុចចាប់ផ្តើមដ៏ល្អមួយ តែដោយឡែករបាំបង្កើតថ្មីទាំងនេះ ត្រូវធ្វើការសាកល្បង និងបង្ហាញទៅទស្សនិកជនឱ្យបានច្រើនដង ដើម្បីទទួលបាននូវការ គាំទ្រដែលជាកត្តាមួយដ៏សំខាន់ក្នុងការជម្រុញឱ្យរបាំទាំងនេះ ក្លាយទៅជារបាំដែលសាធារណជនទទួលស្គាល់ឱ្យតម្លៃ និងអាចចូលបានទៅនៅក្នុងបញ្ជីអចិន្ត្រៃយ៍ ដូចជា របាំប្រពៃណីផ្សេងៗទៀតដែលមកពីមុន។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង